# ព្រះរាជក្រម

នស/រកម/០១១១/០០១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ

**មាត្រា ១.–**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៣.–**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១១

នស/រកម. ០១១១.០០១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

អង្គ ឧង្ស ឧឡារា

ចំលងចេញពីច្បាប់ដើម ... ចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មករា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនគេន

# កិច្ចព្រមព្រៀងស្តីពីបត្យាប័ន
# រវាង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ (ដែលតទៅនេះកំណត់ហៅថា "គូភាគី")

ដោយមានបំណងជំរុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធភាពរវាងប្រទេសទាំងពីរ ក្នុងការលុបបំបាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពគ្នាទៅវិញទៅមកនូវអធិបតេយ្យភាព សមភាព និងផលប្រយោជន៍ទាំងសងខាង តាមការចុះកិច្ចព្រមព្រៀងបត្យាប័ន។

បានព្រមព្រៀងគ្នាដូចតទៅៈ

## មាត្រា១
## កាតព្វកិច្ចធ្វើបត្យាប័ន

ដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗមានភារកិច្ចធ្វើបត្យាប័នទៅភាគីម្ខាងទៀត នូវជនទាំងឡាយណា ដែលត្រូវបានឃើញនៅលើទឹកដីនៃភាគីណាមួយ ហើយដែលកំពុងត្រូវគេតាមចាប់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ធ្វើការជំនុំជម្រះក្តី ឬអនុវត្តទណ្ឌកម្មតាមទោសកំណត់ នៅលើទឹកដីរបស់ភាគីម្ខាងទៀត ចំពោះបទល្មើសណាមួយដែលអាចធ្វើបត្យាប័នបាន។

## មាត្រា២
## បទល្មើសដែលអាចធ្វើបត្យាប័នបាន

ក្នុងស្មារតីនៃកិច្ចព្រមព្រៀងនេះ បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមច្បាប់ជាធរមានរបស់ភាគីទាំងពីរ ដោយការដាក់ពន្ធនាគារឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំង សម្រាប់រយៈពេលយ៉ាងតិច២ឆ្នាំ ឬការផ្តន្ទាទោសដែលធ្ងន់ជាងនេះ។

២. កាលណាមានសំណើបត្យាប័នពាក់ព័ន្ធនឹងបុគ្គលណាម្នាក់ ដែលត្រូវបានកាត់ទោសជាប់ពន្ធនាគារឬការឃុំឃាំងតាមរូបភាពណាមួយផ្សេងទៀតដោយតុលាការរបស់ភាគីដាក់សំណើចំពោះបទល្មើសដែលអាចធ្វើបត្យាប័នណាមួយ បត្យាប័នអាចនឹងផ្តល់បាន លុះត្រាតែទោសកំណត់ដែលត្រូវទទួល ដូចមានចែងក្នុងសាលក្រម/សាលដីកា នៅសល់យ៉ាងតិចបំផុត៦ខែទៀត។

៣. ក្នុងស្មារតីនៃមាត្រានេះ ការកំណត់ថា បទល្មើសណាមួយជាបទល្មើសប្រឆាំងនឹងអង្គច្បាប់នៃភាគីទាំងពីរ គឺមិនសំខាន់ត្រង់ថា អង្គច្បាប់នៃភាគី ចាត់ទុកជាអំពើឬការខកខានដែលបង្កនូវបទល្មើសនោះ ក្នុងប្រភេទនៃបទល្មើសដូចគ្នា ឬកំណត់បទល្មើសដោយប្រើពាក្យពេចន៍ដូចគ្នានោះទេ។

៤.ប្រសិនបើសំណើសុំបត្យាប័ននេះ យោងលើបទល្មើសជាច្រើនដាច់ដោយឡែកពីគ្នា ដែលបទល្មើសនីមួយៗគឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមច្បាប់ជាធរមានរបស់ភាគីទាំងពីរ ប៉ុន្តែបទល្មើសមួយចំនួនមិនបានបំពេញទៅនឹងលក្ខខណ្ឌផ្សេងទៀត ដូចបានចែងនៅក្នុងកថាខណ្ឌ១និង២នៃមាត្រានេះ បត្យាប័នអាចនឹងត្រូវបានផ្តល់ឱ្យចំពោះបទល្មើសក្រោយៗ ដរាបណាបុគ្គលនោះត្រូវបានធ្វើបត្យាប័ន យ៉ាងហោចណាស់បទល្មើសមួយដែលអាចធ្វើបត្យាប័នបាន។

៥. ក្នុងករណីដែលបទល្មើសត្រូវបានប្រព្រឹត្ត នៅក្រៅដែនដីនៃភាគីដាក់សំណើ បត្យាប័ននឹងត្រូវបានផ្តល់ឱ្យ ក្នុងករណីដែលច្បាប់របស់ភាគីទទួលសំណើចែងអំពីការផ្តន្ទាទោសនៃបទល្មើសដែលប្រព្រឹត្តនៅក្រៅដែនដីនៅក្នុងកាលៈទេសៈស្រដៀងគ្នា។ ករណីដែលច្បាប់នៃភាគីទទួលសំណើមិនមានចែងដូច្នេះ ភាគីទទួលសំណើអាចផ្តល់បត្យាប័ន ដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

## មាត្រា៣
## មូលដ្ឋានដាច់ខាតសម្រាប់ធ្វើការបដិសេធ

ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ បត្យាប័នមិនអនុញ្ញាតឱ្យផ្តល់បានឡើយ ក្នុងករណីមួយចំនួន ដូចខាងក្រោម៖

១. ភាគីទទួលសំណើយល់ឃើញថា បទល្មើសជាកម្មវត្ថុនៃបត្យាប័ន ដែលធ្វើឡើងដោយភាគីដាក់សំណើ ជាបទល្មើសនយោបាយ។ ការយោងទៅលើបទល្មើសនយោបាយ ពុំត្រូវរាប់បញ្ចូលនូវបទល្មើសមួយចំនួន ដូចខាងក្រោមនេះ៖

(ក) ការធ្វើឃាត ឬការប៉ុនប៉ងធ្វើឃាត ឬការបំពារបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល ឬសមាជិកគ្រួសារនៃវរជនទាំងនោះ។

(ខ) បទល្មើសមួយដែលភាគីមានកាតព្វកិច្ចបង្កើតយុត្តាធិការឬធ្វើបត្យាប័ន ដោយមូលហេតុ កិច្ចព្រមព្រៀងអន្តរជាតិពហុភាគីដែលភាគីទាំងពីរជាភាគី រួមបញ្ចូល ប៉ុន្តែមិនកំណត់នូវកិច្ចព្រមព្រៀង ទាក់ទងនឹងបទប្រល័យពូជសាសន៍ ភេរវកម្ម ឬការចាប់ចំណាប់ខ្មាំង។

២. ភាគីទទួលសំណើមានមូលដ្ឋានច្បាស់លាស់ ដើម្បីសន្មតថា សំណើបត្យាប័នធ្វើឡើងដោយភាគីដាក់សំណើ មានគោលបំណងប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំងឬអនុវត្តទណ្ឌកម្មទៅលើបុគ្គលដែលត្រូវចោទប្តឹងដោយមូលហេតុពូជសាសន៍ សាសនា សញ្ជាតិ ឬទស្សនៈនយោបាយរបស់បុគ្គលនោះ ឬក៏គំនិតនយោបាយ ឬថា ជំហររបស់ជនដែលត្រូវចោទប្តឹងក្នុងរឿងក្តីនោះ នឹងត្រូវបានធ្វើឱ្យប៉ះពាល់ដោយសារហេតុផលពោលខាងលើ។

៣. បទល្មើសដែលជាកម្មវត្ថុនៃសំណើបត្យាប័ន ត្រូវបានធ្វើឡើង ដោយមិនរួមបញ្ចូលចំពោះបទល្មើសដែលមានចែងនៅក្នុងច្បាប់យោធារបស់ភាគីដាក់សំណើ ដែលមិនមែនជាបទល្មើសដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌធម្មតាឡើយ។

៤. ការចោទប្រកាន់ឬការអនុវត្តការដាក់ទណ្ឌកម្មចំពោះបទល្មើសណាមួយ ដែលកម្មវត្ថុរបស់បត្យាប័ន ត្រូវបានរាំងស្ទះដោយមូលហេតុមានចែងក្នុងច្បាប់នៃភាគីនីមួយៗណាមួយ ដោយរាប់បញ្ចូលទាំងច្បាប់ស្តីពីអាជ្ញាយុកាល។

៥. ភាគីទទួលសំណើបានកាត់ទោសនិងផ្តន្ទាទោស ឬលើកលែងការចោទប្រកាន់លើបុគ្គលដែលត្រូវស្នើសុំ ចំពោះបទល្មើសដដែលនេះរួចហើយ មុនពេលដាក់សំណើសុំធ្វើបត្យាប័ន។

៦. ប្រសិនបើសាលក្រម/សាលដីការបស់ភាគីដាក់សំណើបានត្រូវធ្វើឡើងដោយកំបាំងមុខជនជាប់ទោសពុំបានទទួលព័ត៌មានគ្រប់គ្រាន់ អំពីសវនាការកាត់ក្តីនេះ ឬគ្មានឱកាសចាត់ចែង ការការពារក្តីរបស់ខ្លួន ឬគ្មានឱកាសដើម្បីឱ្យសំណុំរឿងក្តីរបស់ខ្លួនបានត្រូវជំនុំជម្រះឡើងវិញ ដោយមានវត្តមានរបស់ខ្លួន។

## មាត្រា៤
## មូលដ្ឋាននៃការបដិសេធដោយឆន្ទានុសិទ្ធិ

ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ បត្យាប័នអាចបដិសេធបាន ក្នុងករណីដូចខាងក្រោមនេះ៖

១. យោងតាមច្បាប់របស់ខ្លួន ភាគីទទួលសំណើមានយុត្តាធិការលើបទល្មើស ដែលជាកម្មវត្ថុនៃសំណើបត្យាប័ន។ ក្នុងករណីនេះអាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួលសំណើ ត្រូវរៀបចំនីតិវិធីជុំនំជម្រះជនដែលត្រូវស្នើសុំ ធ្វើបត្យាប័ន។

២. ក្នុងករណីពិសេសទាំងឡាយ ដោយគិតពីភាពធ្ងន់ធ្ងរនៃបទល្មើសនិងផលប្រយោជន៍របស់ភាគីដាក់សំណើ ភាគីទទួលសំណើអាចពិនិត្យឃើញថា បត្យាប័ននេះមានវិសមិតភាពទៅនឹងទស្សនវិស័យផ្នែកមនុស្សធម៌ ដោយសារស្ថានភាពផ្ទាល់របស់ជនដែលត្រូវស្នើសុំ។

៣. ភាគីទទួលសំណើ កំពុងដំណើការរៀបចំនីតិវិធីជុំនំជម្រះជនដែលត្រូវស្នើសុំបត្យាប័នចំពោះបទល្មើសដូចគ្នា។

៤. ប្រសិនបើបុគ្គលដែលត្រូវស្នើឱ្យធ្វើបត្យាប័ន ត្រូវបានគេកាត់ទោស ឬនឹងត្រូវចូលសវនាការ ឬកាត់ទោសនៅក្នុងទឹកដីនៃភាគីដាក់សំណើ ដោយតុលាការពិសេសឬសាលាជម្រះក្តី។

៥. ប្រសិនបើបុគ្គលដែលត្រូវស្នើសុំធ្វើបត្យាប័ន ត្រូវបានដោះលែងជាស្ថាពរ ឬកាត់ទោសនៅក្នុងរដ្ឋទី៣ ចំពោះបទល្មើសដូចគ្នាដែលបត្យាប័នត្រូវបានស្នើឡើង និងប្រសិនបើត្រូវបានកាត់ទោស ទោសដែលត្រូវបានដាក់ ត្រូវបានអនុវត្តពេញលេញឬលែងអនុវត្តទៀតហើយ។

## មាត្រា៥
## ការធ្វើបត្យាប័នចំពោះពលរដ្ឋសាមី

១. ភាគីនីមួយៗ មានសិទ្ធិបដិសេធការធ្វើបត្យាប័នពលរដ្ឋផ្ទាល់របស់ខ្លួន។

២. ប្រសិនបើបត្យាប័នមិនត្រូវបានផ្តល់ឱ្យ អនុលោមតាមកថាខណ្ឌ១នៃមាត្រានេះ ភាគីទទួលសំណើត្រូវបញ្ជូនសំណុំរឿងនេះ ទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ទៅស្ថាប័នអយ្យការរបស់ភាគីដាក់សំណើ។ ក្នុងករណីនេះ ភាគីដាក់សំណើត្រូវបញ្ជូនឯកសារនិងភស្តុតាងដែលទាក់ទងនឹងសំណុំរឿងនេះ ទៅភាគីទទួលសំណើ។

៣. ទោះបីកថាខណ្ឌ២នៃមាត្រានេះបានចែងដូច្នេះក៏ដោយ ភាគីទទួលសំណើពុំចាំបាច់បញ្ជូនសំណុំរឿងនេះ ទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីចោទប្រកាន់ទេ ប្រសិនបើភាគីទទួលសំណើគ្មានយុត្តាធិការលើបទល្មើសនេះ។

៤. សញ្ជាតិត្រូវកំណត់នៅពេលដែលប្រព្រឹត្តបទល្មើស នៅពេលដែលបត្យាប័នត្រូវបានស្នើ។

## មាត្រា៦
## វិធីផ្តល់ព័ត៌មាន

ក្នុងស្មារតីនៃកិច្ចព្រមព្រៀងនេះ គូភាគីត្រូវធ្វើការប្រាស្រ័យទាក់ទងគ្នា តាមរយៈផ្លូវទូត វៀរលែងតែមាន បទប្បញ្ញត្តិផ្សេងចែងក្នុងកិច្ចព្រមព្រៀងនេះ។

## មាត្រា៧
## សំណើបត្យាប័ននិងឯកសារចាំបាច់ដែលត្រូវភ្ជាប់ជាមួយ

១. សំណើបត្យាប័នត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវភ្ជាប់មកជាមួយនូវៈ

ក. ឯកសារ សេចក្តីបញ្ជាក់ ឬព័ត៌មានផ្សេងទៀត ដែលពិពណ៌នាអំពីអត្តសញ្ញាណ ប្រសិនបើមាន រួមបញ្ចូលទាំងការពិពណ៌នាអំពីប្រវត្តិសង្ខេប រូបថត និង/ឬស្នាមមេដៃ សញ្ជាតិ និងទីកន្លែងស្នាក់នៅប្រហាក់ប្រហែលរបស់ជនដែលត្រូវស្នើសុំ។

ខ. សេចក្តីបញ្ជាក់លើអង្គហេតុនៃសំណុំរឿង រួមបញ្ចូលទាំងពេលវេលា និងទីកន្លែងប្រព្រឹត្តបទល្មើស និងប្រវត្តិនីតិវិធីនៃសំណុំរឿង។

គ.សេចក្តីបញ្ជាក់អំពីច្បាប់ដែលពិពណ៌នាអំពីធាតុផ្សំសំខាន់ៗនិងការកំណត់នៃបទ-ល្មើស។

ឃ. សេចក្តីបញ្ជាក់អំពីច្បាប់ដែលពិពណ៌នាអំពីការដាក់ទណ្ឌកម្មចំពោះបទល្មើស។

ង. សេចក្តីបញ្ជាក់អំពីច្បាប់ដែលទាក់ទងនឹងការកំណត់ពេលនៃការចោទប្រកាន់ឬការអនុវត្តទណ្ឌកម្ម ចំពោះបទល្មើស។ និង

ច. ឯកសារ សេចក្តីបញ្ជាក់ ឬព័ត៌មានផ្សេងទៀតដែលបញ្ជាក់នៅក្នុងកថាខណ្ឌ២ ឬ ៣នៃមាត្រានេះ ប្រសិនបើមាន។

២. សំណើបត្យាប័នទាក់ទងនឹងជនដែលត្រូវស្នើសុំ ដើម្បីចោទប្រកាន់ ត្រូវភ្ជាប់ជាមួយផងដែរនូវ៖

ក. សេចក្តីចម្លងនៃដីកាចាប់ខ្លួនឬដីកាឃុំខ្លួន ចេញដោយចៅក្រមឬអាជ្ញាធរមានសមត្ថកិច្ច តុលាការដទៃទៀត របស់ភាគីដាក់សំណើ។

ខ. ព័ត៌មានដែលបញ្ជាក់ថា បុគ្គលដែលស្នើសុំបត្យាប័ន គឺជាបុគ្គលដែលមានដីកាចាប់ខ្លួនឬដីកាឃុំខ្លួន។ និង

គ. សេចក្តីបញ្ជាក់នៃអំពើឬការខកខានដែលបានចោទប្រកាន់ បង្កើតបានជាបទល្មើស និងភស្តុតាងគាំទ្រដែលអាចផ្តល់នូវមូលដ្ឋានត្រឹមត្រូវ គួរឱ្យសង្ស័យថា បុគ្គលដែលត្រូវធ្វើបត្យាប័ន បានប្រព្រឹត្តបទល្មើសដែលបត្យាប័នត្រូវបានស្នើឡើង។

៣. កាលណាសំណើបត្យាប័នទាក់ទងនឹងជនដែលត្រូវបានគេឃើញនូវពិរុទ្ធ សំណើនេះក៏ត្រូវភ្ជាប់មកជាមួយផងដែរនូវ៖

ក.សេចក្តីចម្លងសាលក្រម/សាលដីកាចេញដោយតុលាការនៃភាគីដាក់សំណើ ដែលកំណត់អំពីការកាត់ទោសនិងទោសដែលបានដាក់ អង្គហេតុដែលទោសអាចអនុវត្តបាននិងបរិបទដែលទោសនៅមិនទាន់ទទួល។

ខ.សេចក្តីចម្លងនៃដីកាចាប់ខ្លួនឬសេចក្តីបញ្ជាក់ថា បុគ្គលជាកម្មវត្ថុនៃការឃុំខ្លួន ផ្អែកលើមូលដ្ឋាននៃសាលក្រម/សាលដីកាកាត់ទោស។

គ. ព័ត៌មានដែលបញ្ជាក់ថា បុគ្គលដែលស្នើបត្យាប័ន គឺជាបុគ្គលដែលមានពិរុទ្ធ។

ឃ. សេចក្តីបញ្ជាក់នៃអំពើឬការខកខានដែលអាចបង្កើតបានជាបទល្មើស ដែលបុគ្គលនោះត្រូវបានគេឃើញថាមានពិរុទ្ធ។

ង. សេចក្តីបញ្ជាក់ទាក់ទងនឹងមធ្យោបាយតាមផ្លូវច្បាប់ ដែលកើតមានចំពោះបុគ្គល ដើម្បីរៀបចំការការពារខ្លួនរបស់គេឬក៏ចាត់ឱ្យមានការកាត់ក្តីសាឡើងវិញ ដោយមានវត្តមានបុគ្គលនោះ ប្រសិនបើបុគ្គលត្រូវផ្តន្ទាទោសចំពោះបទល្មើសណាមួយ ពុំមានវត្តមាន។

៤. រាល់ឯកសារទាំងឡាយដែលភាគីដាក់សំណើបញ្ជូនមក អនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវចុះហត្ថលេខាឬបោះត្រាជាផ្លូវការនិងភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសានៃភាគីទទួលសំណើឬជាភាសាអង់គ្លេស។

## មាត្រា៨
## ព័ត៌មានបន្ថែម

១. ប្រសិនបើភាគីទទួលសំណើយល់ឃើញថា ព័ត៌មានដែលផ្តល់សម្រាប់គាំទ្រសំណើបត្យាប័ន ពុំមានលក្ខណៈគ្រប់គ្រាន់ ស្របតាមកិច្ចព្រមព្រៀង សម្រាប់ផ្តល់ការយល់ព្រមលើបត្យាប័ន ភាគីនោះអាចស្នើសុំផ្តល់ព័ត៌មានបន្ថែមពីភាគីដាក់សំណើ ក្នុងរយៈពេលកំណត់ណាមួយសមស្រប។ ប្រសិនបើភាគីដាក់សំណើខកខានពុំបានបញ្ជូនព័ត៌មានបន្ថែមតាមរយៈពេលកំណត់នោះ នឹងត្រូវចាត់ទុកថាបានលះបង់នូវសំណើរបស់ខ្លួន ដោយស្ម័គ្រចិត្ត។ ប៉ុន្តែភាគីដាក់សំណើមិនត្រូវបានហាមឃាត់មិនឱ្យធ្វើសំណើនេះជាថ្មីទៀតនោះទេ។

២. ក្នុងករណីដែលបុគ្គលនោះត្រូវបានគេដោះលែងពីការឃុំឃាំង យោងតាមកថាខណ្ឌ១ នៃមាត្រានេះ ភាគីទទួលសំណើត្រូវតែជូនដំណឹងដល់ភាគីដាក់សំណើ កាន់តែឆាប់កាន់តែប្រសើរ។

## មាត្រា៩
## ការចាប់ខ្លួនបណ្តោះអាសន្ន

១. ក្នុងករណីបន្ទាន់ ភាគីមួយអាចស្នើទៅភាគីម្ខាងទៀត ឱ្យធ្វើការចាប់ខ្លួនបណ្តោះអាសន្ននូវបុគ្គល ដែលត្រូវស្នើសុំ។ សំណើនេះអាចដាក់ជូនជាលាយលក្ខណ៍អក្សរតាមផ្លូវទូត។

២. សំណើសុំចាប់ខ្លួនបណ្តោះអាសន្ន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមាន៖

(ក) ការពិពណ៌នាអំពីជនដែលត្រូវស្នើសុំ រួមទាំងព័ត៌មានអំពីសញ្ជាតិនៃបុគ្គលនោះ។

(ខ) សេចក្តីបញ្ជាក់នៃទីកន្លែង ដែលជននោះស្ថិតនៅ ប្រសិនបើដឹង។

(គ) សេចក្តីបញ្ជាក់សង្ខេប អំពីអង្គហេតុនៃសំណុំរឿង ប្រសិនបើមានពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តបទល្មើស។

(ឃ) ការពិពណ៌នាអំពីច្បាប់ដែលបានរំលោភ។

(ង) សេចក្តីបញ្ជាក់ថា មានដីកាចាប់ខ្លួនឬសាលក្រម/សាលដីកានៃការកាត់ទោសលើជននោះ។ និង

(ច) សេចក្តីបញ្ជាក់អំពីសំណើបត្យាប័នលើជនដែលត្រូវស្នើសុំ នឹងត្រូវបញ្ជូនតាមក្រោយ។

៣. ភាគីដាក់សំណើនឹងត្រូវបានទទួលដំណឹងពីលទ្ធផលនៃសំណើរបស់ខ្លួន ដោយគ្មានបង្អែបង្អង់។

៤. ការចាប់ខ្លួនបណ្តោះអាសន្ននឹងត្រូវបញ្ចប់ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួលសំណើ ពុំបានទទួលសំណើបត្យាប័នជាផ្លូវការនិងឯកសារសំអាងនានា ដូចដែលកំណត់ក្នុងមាត្រា៧ ក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ពីការចាប់ខ្លួនជននោះ។ កថាខណ្ឌនោះ មិនត្រូវរាំងលទ្ធភាពនៃការដោះលែង ដោយមានលក្ខខណ្ឌ នូវជនដែលត្រូវស្នើសុំមុនផុតរយៈពេល៦០ថ្ងៃនេះទេ ក្នុងករណីដែលភាគីទទួលសំណើមានមូលដ្ឋានបដិសេធដាច់ខាតឬមូលដ្ឋានបដិសេធដោយឆន្ទានុសិទ្ធិ ឬប្រសិនបើភាគីដាក់សំណើលុបចោលនូវសំណើបត្យាប័នរបស់ខ្លួន។

៥. ការដោះលែងជនដែលស្នើសុំពីការឃុំឃាំង អនុលោមតាមកថាខណ្ឌ៤នៃមាត្រានេះ មិនត្រូវធ្វើឱ្យជលប៉ះពាល់ដល់ការចាប់ខ្លួនឡើងជាបន្តបន្ទាប់និងការធ្វើបត្យាប័នជននោះទេ ប្រសិនបើសំណើបត្យាប័ននិងរាល់ឯកសារសំអាងនានាត្រូវបានផ្តល់ជូននៅពេលក្រោយ។

## មាត្រា១០
## ការធ្វើបត្យាប័នសាមញ្ញ

នៅពេលដែលបុគ្គលដែលស្នើសុំបត្យាប័នប្រាប់តុលាការឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតនៃភាគីទទួលសំណើ ថាបុគ្គលនោះយល់ព្រមមានការធ្វើបត្យាប័នដែលកំពុងស្នើឡើង ភាគីទទួលសំណើអាចចាត់វិធានការចាំបាច់នានា ដើម្បីពន្លឿនការធ្វើបត្យាប័ន ក្នុងកម្រិតដែលច្បាប់របស់ខ្លួនអនុញ្ញាតឱ្យ។

## មាត្រា១១
## ការសម្រេចចិត្តទៅលើការស្នើ

១. ភាគីទទួលសំណើត្រូវពិនិត្យសំណើសុំបត្យាប័ន ស្របតាមនីតិវិធីដែលច្បាប់របស់ខ្លួនកំណត់ឱ្យ និងត្រូវផ្តល់សេចក្តីសម្រេចរបស់ខ្លួនទៅភាគីដាក់សំណើ។

២.មូលហេតុនៃការបដិសេធទាំងស្រុងឬដោយអន្លើណាមួយលើសំណើសុំបត្យាប័ននោះ ត្រូវតែផ្តល់ជូន។

## មាត្រា១២
## ការប្រគល់ខ្លួនជនដែលត្រូវស្នើសុំ

១. ប្រសិនបើបត្យាប័នត្រូវបានផ្តល់ឱ្យ ភាគីទទួលសំណើ និងភាគីដាក់សំណើ ត្រូវសម្រេចអំពីការអនុវត្តបត្យាប័នតាមរយៈការពិគ្រោះយោបល់គ្នា។ សម្រាប់គោលបំណងនេះ ភាគីទទួលសំណើត្រូវជូនព័ត៌មានដល់ភាគីដាក់សំណើ អំពីរយៈពេលដែលជនដែលត្រូវស្នើសុំនោះត្រូវបានចាប់ឃុំឃាំង មុនពេលប្រគល់ខ្លួន។

២. ល្គឹកណាកថាខណ្ឌ៣នៃប្រការនេះមិនមានចែងអ្វីមួយផ្ទុយពីនេះ ភាគីដាក់សំណើត្រូវបានចាត់ទុកថាបានបោះបង់សំណើបត្យាប័ន ប្រសិនបើភាគីនេះពុំទទួលយកជនដែលត្រូវបានស្នើសុំក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីថ្ងៃដែលការអនុវត្តបត្យាប័នត្រូវបានព្រមព្រៀងគ្នារួចហើយ។ ភាគីទទួលសំណើត្រូវដោះលែងជននោះ ឱ្យមានសេរីភាពជាបន្ទាន់ ហើយអាចបដិសេធធ្វើបត្យាប័នចំពោះបទល្មើសដដែលនេះ។

៣. ប្រសិនបើភាគីណាមួយខកខានពុំបានប្រគល់ឬទទួលយកជនដែលត្រូវស្នើសុំ ក្នុងចិរវេលាដែលបានព្រមព្រៀងគ្នា ដោយករណីប្រធានសក្តិ ភាគីម្ខាងទៀតត្រូវតែបានគេជូនព័ត៌មានពីបញ្ហានេះ។ គូភាគីត្រូវសម្រេចជាថ្មីម្តងទៀត តាមការពិគ្រោះយោបល់គ្នា អំពីការអនុវត្តបត្យាប័ន ហើយបទប្បញ្ញត្តិនៃកថាខណ្ឌ២នៃមាត្រានេះនឹងត្រូវអនុវត្ត។

## មាត្រា១៣
## ការពន្យារពេលនៃការប្រគល់ខ្លួនឬការប្រគល់ខ្លួនជាបណ្តោះអាសន្ន

១. នៅពេលណាដែលជនត្រូវស្នើសុំកំពុងត្រូវស្ថិតក្នុងនីតិវិធីជំនុំជម្រះក្តីឬកំពុងទទួលទោសក្នុងទឹកដីនៃភាគីទទួលសំណើ ចំពោះបទល្មើសណាមួយផ្សេងពីបទល្មើសដែលជាកម្មវត្ថុបត្យាប័ន ភាគីទទួលសំណើអាចប្រគល់ឬពន្យារការប្រគល់ជននោះ ហូតដល់ការបញ្ចប់នីតិវិធីជំនុំជម្រះក្តីឬការទទួលទោសទាំងស្រុងឬមួយផ្នែកណានៃទោសដែលកំណត់ក្នុងសាលក្រម/សាលដីកា។ ភាគីទទួលសំណើត្រូវជូនដំណឹងទៅភាគីដាក់សំណើ អំពីការពន្យារពេលនេះ។

២. ក្នុងកម្រិតមួយដែលច្បាប់របស់ខ្លួនអនុញ្ញាតឱ្យ នៅពេលដែលជនម្នាក់ត្រូវបានរកឃើញថា អាចធ្វើបត្យាប័នបាន ភាគីទទួលសំណើអាចប្រគល់ជនដែលត្រូវស្នើសុំជាបណ្តោះអាសន្ន ទៅភាគីដាក់សំណើ ដើម្បីធ្វើការចោទប្រកាន់ ស្របទៅតាមលក្ខខណ្ឌដែលបានកំណត់រវាងគូភាគី។ ជនណាម្នាក់ដែលត្រូវបានប្រគល់ទៅភាគីទទួលសំណើ បន្ទាប់ពីការប្រគល់ខ្លួនបណ្តោះអាសន្ន អាចត្រូវប្រគល់ជាស្ថាពរទៅភាគីដាក់សំណើ ដើម្បីទទួលទោសតាមសាលក្រម/សាលដីកាកំណត់ ស្របតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា១៤
## សំណើបត្យាប័នធ្វើឡើងដោយរដ្ឋច្រើន

១. ក្នុងករណីដែលសំណើត្រូវបានទទួលពីរដ្ឋពីរឬច្រើន រួមទាំងភាគីដទៃទៀត សម្រាប់ការធ្វើបត្យាប័នបុគ្គលដដែល ទោះបីជាបទល្មើសដូចគ្នាក្តីឬខុសគ្នាក្តី ភាគីទទួលសំណើត្រូវកំណត់ថាតើត្រូវធ្វើបត្យាប័នបុគ្គលនោះ ទៅឱ្យរដ្ឋណាមួយក្នុងចំណោមរដ្ឋទាំងនោះ ហើយត្រូវតែជូនដំណឹងទៅរដ្ឋទាំងនោះពីការសម្រេចចិត្តរបស់ខ្លួន។

២. ការកំណត់រដ្ឋណាមួយដែលបុគ្គលនោះត្រូវធ្វើបត្យាប័ន រដ្ឋទទួលសំណើត្រូវពិចារណាលើកត្តាពាក់ព័ន្ធទាំងអស់ មានជាអាទិ៍៖

(ក) សញ្ជាតិនិងទីលំនៅរបស់ជនដែលត្រូវធ្វើបត្យាប័ន។

(ខ) សំណើធ្វើឡើងថាតើស្របតាមកិច្ចព្រមព្រៀងឬទេ។

(គ) ពេលវេលានិងទីកន្លែងនៃការប្រព្រឹត្តបទល្មើសនីមួយៗ។

(ឃ) ផលប្រយោជន៍ដាច់ដោយឡែករបស់រដ្ឋដាក់សំណើ។

(ង) ស្ថានទម្ងន់ទោស។

(ច) សញ្ជាតិនៃជនរងគ្រោះ។

(ឆ) លទ្ធភាពនៃការធ្វើបត្យាប័នបន្ថែមទៀតរវាងភាគីដាក់សំណើនានា។ និង
(ជ) កាលបរិច្ឆេទខុសគ្នានៃសំណើ។

## មាត្រា១៥
## វិធានពិសេស

១. បុគ្គលដែលត្រូវធ្វើបត្យាប័ន អនុលោមតាមកិច្ចព្រមព្រៀងនេះ មិនត្រូវទទួលការឃុំឃាំង ទទួលការកាត់ក្តីឬការដាក់ទណ្ឌកម្ម នៅក្នុងទឹកដីនៃភាគីដាក់សំណើ សម្រាប់បទល្មើសណាមួយ ក្រៅពីបទល្មើសដែលបត្យាប័នបានត្រូវផ្តល់ជូន វៀរលែងតែភាគីទទួលសំណើយល់ព្រមឱ្យមានការ ឃុំខ្លួនបុគ្គល ការកាត់ទោស ឬការផ្តន្ទាទោស។ សម្រាប់ការយល់ព្រមនេះ មានយោងក្នុងកថាខណ្ឌ នេះ៖

ក. ភាគីទទួលសំណើអាចតម្រូវឱ្យដាក់ជូននូវឯកសារដែលមានចែងក្នុងមាត្រា៧។

ខ. សេចក្តីបញ្ជាក់ដែលធ្វើឡើងដោយបុគ្គលដែលត្រូវធ្វើបត្យាប័នទាក់ទងនឹងបទល្មើស ប្រសិនបើមាន ត្រូវដាក់ជូនទៅភាគីទទួលសំណើ។ និង

គ. បុគ្គលដែលត្រូវធ្វើបត្យាប័នអាចធ្វើការឃុំខ្លួន ដោយភាគីដាក់សំណើ សម្រាប់ រយៈពេល ដូចដែលភាគីទទួលសំណើអាចអនុញ្ញាតឱ្យ ខណៈដែលសំណើសុំការព្រមព្រៀងយោង មាត្រានេះ កំពុងតែដំណើរការ។

២. បុគ្គលដែលត្រូវធ្វើបត្យាប័នក្រោមកិច្ចព្រមព្រៀងនេះ មិនត្រូវបានធ្វើបត្យាប័នឡើងវិញ ដោយភាគី ដាក់សំណើទៅរដ្ឋទី៣ សម្រាប់បទល្មើសដែលបានប្រព្រឹត្ត មុនពេលធ្វើបត្យាប័នជន នោះទេ វៀរលែងតែភាគីទទួលសំណើយល់ព្រម។

៣. បុគ្គលដែលត្រូវធ្វើបត្យាប័ន ក្រោមកិច្ចព្រមព្រៀងនេះ មិនត្រូវឃុំខ្លួន មិនត្រូវបានកាត់ទោស និងមិនត្រូវបានផ្តន្ទាទោស នៅក្នុងភាគីដាក់សំណើ សម្រាប់បទល្មើសណាមួយក្រៅពីបទល្មើស ដែលបត្យាប័នត្រូវបានយល់ព្រម ហើយមិនត្រូវបានធ្វើបត្យាប័នឡើងវិញទៅរដ្ឋទី៣ វៀរលែងតែ បុគ្គលដែលត្រូវធ្វើបត្យាប័ន៖

(ក) បានវិលត្រឡប់មកដែនដីភាគីដាក់សំណើដោយស្ម័គ្រចិត្ត បន្ទាប់ពីការចាកចេញ។ ឬ

(ខ)មិនបានចាកចេញពីដែនដីភាគីដាក់សំណើ ក្នុងអំឡុងពេល៣០ថ្ងៃ ចាប់ពីថ្ងៃដែលបុគ្គលនោះ ត្រូវបានផ្តល់សិទ្ធិឱ្យចាកចេញ លើកលែងតែនៅក្រោមលក្ខខណ្ឌហួសពីការត្រួតពិនិត្យរបស់ខ្លួន។

៤. បទប្បញ្ញត្តិទាំងនេះមិនត្រូវអនុវត្តទេ ចំពោះបទល្មើសទាំងឡាយណាដែលបានប្រព្រឹត្តក្រោយការធ្វើបត្យាប័ន។

## មាត្រា១៦
## ការប្រគល់ទ្រព្យសម្បត្តិ

១. ក្នុងកម្រិតមួយដែលច្បាប់របស់ខ្លួនអនុញ្ញាតឱ្យ និងយោងតាមសំណើនៃភាគីដាក់សំណើ ភាគីទទួលសំណើត្រូវរឹបអូសទ្រព្យសម្បត្តិ និងក្រោយពីបានផ្តល់បត្យាប័ន ត្រូវប្រគល់ទ្រព្យសម្បត្តិ៖

(ក) ដែលអាចតម្រូវឱ្យធ្វើជាភស្តុតាង។ ឬ

(ខ) ដែលត្រូវបានទទួល ដោយសារលទ្ធផលនៃបទល្មើស។

២. ទ្រព្យសម្បត្តិ ដូចមានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ ត្រូវប្រគល់ជូន ទោះបីការធ្វើបត្យាប័នដែលត្រូវបានផ្តល់ឱ្យ មិនអាចអនុវត្តបាន ដោយមូលហេតុមកពីមរណភាព ការបាត់ខ្លួន ឬការគេចខ្លួននៃជនដែលត្រូវជាប់ចោទ។

៣. កាលណាទ្រព្យសម្បត្តិខាងលើនេះ ជាកម្មវត្ថុនៃការដកហូតឬការរឹបអូសនៅក្នុងទឹកដីនៃភាគីទទួលសំណើ ភាគីនេះអាចរក្សាទុកជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិទាំងនេះឬបញ្ជូនត្រឡប់ទៅវិញ ក្នុងលក្ខខណ្ឌដែលទ្រព្យសម្បត្តិទាំងនោះ ត្រូវប្រគល់មកឱ្យភាគីទទួលសំណើវិញស្ថិតក្នុងការរង់ចាំនីតិវិធីព្រហ្មទណ្ឌ។

៤. រាល់សិទ្ធិទាំងឡាយណាដែលភាគីទទួលសំណើនៃរដ្ឋណាមួយឬបុគ្គលណាមួយ អាចទទួលបានលើទ្រព្យសម្បត្តិ ដូចពោលខាងលើ ត្រូវរក្សាទុក។ នៅពេលដែលសិទ្ធិនេះនៅមាននៅឡើយ ទ្រព្យសម្បត្តិទាំងនេះត្រូវបញ្ជូនទៅភាគីទទួលសំណើ តាមសំណូមពររបស់ខ្លួន ដោយគ្មានបន្ទុកពន្ធអាករ ឱ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន បន្ទាប់ពីការជំនុំជម្រះក្តី។

## មាត្រា១៧
## ដំណើរឆ្លងកាត់

១. ក្នុងកម្រិតមួយដែលច្បាប់របស់ខ្លួនអនុញ្ញាតឱ្យ ការដឹកជញ្ជូនបុគ្គលដែលត្រូវបត្យាប័នពីរដ្ឋទី៣ទៅកាន់ភាគីណាមួយ ឆ្លងកាត់ទឹកដីនៃភាគីផ្សេងទៀត អាចត្រូវបានអនុញ្ញាតឱ្យ ទៅតាមសំណើជាលាយលក្ខណ៍អក្សរ ធ្វើឡើងតាមរយៈផ្លូវទូត។ សំណើនេះត្រូវពិពណ៌នាអំពីបុគ្គលដែលត្រូវបានដឹកជញ្ជូន រួមបញ្ចូលទាំងសញ្ជាតិរបស់គេនិងសេចក្តីថ្លែងការណ៍សង្ខេបអំពីអង្គហេតុនៃសំណុំរឿង។ បុគ្គលដែលត្រូវឆ្លងកាត់ អាចត្រូវបានឃុំឃាំងក្នុងអំឡុងពេលធ្វើដំណើរឆ្លងកាត់។

២.ការអនុញ្ញាតឱ្យឆ្លងកាត់ មិនតម្រូវឱ្យមានទេ ក្នុងករណីដែលការដឹកជញ្ជូនតាមផ្លូវអាកាសគ្មានការចុះចតគ្រោងទុកជាមុន នៅលើទឹកដីរបស់ភាគីដែលត្រូវគេឆ្លងកាត់។ ប្រសិនបើការចុះចតដែលមិនបានគ្រោងទុកជាមុន កើតមានឡើងនៅលើទឹកដីនៃភាគីនោះ រដ្ឋនោះអាចតម្រូវឱ្យភាគីផ្សេងទៀត ផ្តល់នូវសំណើសុំការឆ្លងកាត់ ដូចមានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ។ ភាគីដែលត្រូវគេឆ្លងកាត់ ត្រូវធ្វើការឃុំខ្លួនបុគ្គលដែលបានដឹកជញ្ជូន រហូតដល់ការដឹកជញ្ជូនត្រូវធ្វើបន្ត ប្រសិនបើទទួលបានសំណើ ក្នុងរយៈពេល៩៦ម៉ោង ចំពោះការចុះចតដែលមិនបានគ្រោងទុកជាមុន។

៣. ការអនុញ្ញាតឱ្យឆ្លងកាត់ ត្រូវរួមបញ្ចូលទាំងការអនុញ្ញាតឱ្យមន្ត្រីអមដំណើរ ទទួលបានកិច្ចឧបត្ថម្ភពីអាជ្ញាធរនៃភាគីដែលត្រូវគេឆ្លងកាត់ ក្នុងការថែរក្សាការឃុំឃាំង។

## មាត្រា១៨
## ការជូនដំណឹងអំពីលទ្ធផល

ភាគីដាក់សំណើត្រូវជូនដំណឹងទៅភាគីទទួលសំណើ ឱ្យទាន់ពេលវេលា នូវព័ត៌មានទាក់ទងនឹងការចោទប្រកាន់ ការជំនុំជម្រះ និងការអនុវត្តនូវការដាក់ទណ្ឌកម្មចំពោះជនដែលស្នើសុំឬការធ្វើបត្យាប័នឡើងវិញនូវជននោះ ទៅរដ្ឋទី៣។

## មាត្រា១៩
## ការឧបត្ថម្ភនិងការចំណាយ

១. ភាគីទទួលសំណើត្រូវចេញមុខក្នុងនាមជាភាគីដាក់សំណើ និងចាត់ចែង ព្រមទាំងអនុវត្តរាល់នីតិវិធីដែលកើតចេញពីសំណើបត្យាប័ន។

២.ភាគីទទួលសំណើត្រូវចេញសោហ៊ុយនៃដំណើរការនីតិវិធីណាមួយ នៅក្នុងយុត្តាធិការរបស់ខ្លួន ដែលកើតឡើងពីសំណើបត្យាប័ន។ ភាគីទទួលសំណើ ត្រូវចេញសោហ៊ុយដែលកើតឡើងនៅក្នុងដែនដីរបស់ខ្លួន ទាក់ទងនឹងការចាប់ខ្លួននិងការឃុំខ្លួននៃជនដែលស្នើសុំបត្យាប័នឬការដកហូតនិងការប្រគល់ទ្រព្យសម្បត្តិ។

៣. ភាគីដាក់សំណើត្រូវចេញសោហ៊ុយដែលកើតឡើងពីការដឹកជញ្ជូនបុគ្គល ដែលបត្យាប័នត្រូវផ្តល់ជូនពីទឹកដីនៃភាគីទទួលសំណើ រួមទាំងសោហ៊ុយធ្វើដំណើរឆ្លងកាត់។

## មាត្រា២០
## ទំនាក់ទំនងជាមួយនឹងអនុសញ្ញាពហុភាគី

កិច្ចព្រមព្រៀងនេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចទាំងឡាយដែលគូភាគីទទួលបាន និងគោរព ក្រោមអនុសញ្ញាពហុភាគីណាមួយឡើយ។

## មាត្រា២១
## ដំណោះស្រាយនៃបញ្ហាវិវាទ

រាល់វិវាទដែលកើតចេញពីការអនុវត្តឬការបកស្រាយនៃកិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយតាមការពិគ្រោះយោបល់ឬការចរចា។

## មាត្រា២២
## ការធ្វើវិសោធនកម្ម

កិច្ចព្រមព្រៀងនេះអាចធ្វើវិសោធនកម្មបាន តាមការស្នើសុំពីភាគីណាមួយ។ រាល់វិសោធនកម្មដែលបានយល់ព្រមដោយគូភាគី តាមរយៈផ្លូវទូត ត្រូវចូលជាធរមានចាប់ពីថ្ងៃដែលបានព្រមព្រៀងគ្នាទៅវិញទៅមក និងត្រូវបង្កើតជាផ្នែករួមមួយនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា២៣
## ការចូលជាធរមាននិងការបញ្ចប់កិច្ចព្រមព្រៀង

១. កិច្ចព្រមព្រៀងនេះចូលជាធរមាន៣០ថ្ងៃបន្ទាប់ពីថ្ងៃដែលគូភាគីបានជូនដំណឹងឱ្យគ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរថា ខ្លួនបានបំពេញបែបបទផ្លូវច្បាប់ផ្ទៃក្នុងចប់សព្វគ្រប់ហើយ សម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។

២. កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះសំណើដែលធ្វើឡើង បន្ទាប់ពីការចូលជាធរមាន សូម្បីតែបទល្មើសពាក់ព័ន្ធបានប្រព្រឹត្តនៅមុនកាលបរិច្ឆេទនៃការចូលជាធរមានក៏ដោយ ។

៣. ភាគីនីមួយៗអាចបញ្ចប់កិច្ចព្រមព្រៀងនេះបាន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរតាមរយៈផ្លូវទូត នៅពេលណាមួយក៏បាន។ ការបញ្ចប់ត្រូវមានអានុភាពប្រាំមួយ(៦)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញពីរដ្ឋាភិបាលសាមីរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

ធ្វើជាពីរច្បាប់ នៅភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំពីរពាន់ប្រាំបួន ជាភាសាខ្មែរ ភាសាកូរ៉េ និង ភាសាអង់គ្លេស។ អត្ថបទនីមួយៗមានតំលៃស្មើៗគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល។

**តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា** **តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ**

## មាត្រា ២៣

## ការចូលជាធរមាន និង ការបញ្ចប់កិច្ចព្រមព្រៀង

១. កិច្ចព្រមព្រៀងនេះចូលជាធរមាន ៣០ ថ្ងៃបន្ទាប់ពីថ្ងៃដែលគូភាគីបានជូនដំណឹងឱ្យគ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរថា ខ្លួនបានបំពេញបែបបទផ្លូវច្បាប់ផ្ទៃក្នុងចប់សព្វគ្រប់ហើយ សំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។

២. កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះសំណើដែលធ្វើឡើង បន្ទាប់ពីការចូលជាធរមាន សូម្បីតែបទល្មើសពាក់ព័ន្ធបានប្រព្រឹត្ត នៅមុនកាលបរិច្ឆេទនៃការចូលជាធរមានក៏ដោយ ។

៣. ភាគីនីមួយៗអាចបញ្ចប់កិច្ចព្រមព្រៀងនេះបាន ដោយជូនដំណឹងជាលាយល័ក្ខអក្សរ តាមរយៈផ្លូវទូតនៅពេលណាមួយក៏បាន ។ ការបញ្ចប់ត្រូវមានអានុភាពប្រាំមួយ (៦) ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង ។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញពីរដ្ឋាភិបាលសាមីរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើជាពីរច្បាប់ នៅភ្នំពេញ ថ្ងៃទី...២៦.....ខែ តុលា ឆ្នាំ ពីពាន់ប្រាំបួន ជាភាសាខ្មែរ ភាសាកូរ៉េ និងភាសាអង់គ្លេស ។ អត្ថបទនីមួយៗមានតំលៃស្មើៗគ្នា ។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល ។

| | |
|---|---|
| **តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា** | **តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ** |

# AGREEMENT ON EXTRADITION

# BETWEEN

# THE GOVERNMENT OF THE KINGDOM OF CAMBODIA

# AND

# THE GOVERNMENT OF THE REPUBLIC OF KOREA

The Government of the Kingdom of Cambodia and the Government of the Republic of Korea (hereinafter referred to as " the Parties");

Desirous of promoting, on the basis of mutual respect for sovereignty, equality and mutual benefit, the effective cooperation between the two countries in the suppression of crime by concluding an agreement on extradition;

Have agreed as follows:

## ARTICLE 1

### Obligation to Extradite

Each Party, in accordance with the provision of this agreement, undertakes to extradite to each other, persons found in the territory of one of the Parties who are wanted for prosecution, trial, or execution of punishment in the territory of the other Party for an extraditable offence.

## ARTICLE 2

### Extraditable Offences

1. For the purpose of this Agreement, extraditable offences are offences which are punishable under the laws of both Parties by imprisonment or other form of detention for a period of at least two years or a more severe penalty.

2. Where the request for extradition relates to a person sentenced to imprisonment or other form of detention by a court of the requesting Party for any extraditable offence, extradition shall be granted only if a period of at least six months in the sentence remains to be served.

3. For the purpose of this Article, in determining whether an offence is an offence against the laws of both Parties, it shall not matter whether the laws of the Parties place the acts or omissions constituting the offence within the same category of offence or denominate the offence by the same terminology.

4. If the request for extradition refers to several separate offences each of which is punishable under the laws of both Parties, but some of which do not fulfill the other conditions set out in paragraphs 1 and 2 of this Article, extradition may be granted for the latter offences provided that the person is to be extradited for at least one extraditable offence.

5. Where the offence has been committed outside the territory of the requesting Party, extradition shall be granted where the law of the requested Party provides for the punishment of an offence committed outside its territory in similar circumstances.

Where the law of the requested Party does not so provide, the requested Party may, in its discretion, grant extradition.

## ARTICLE 3

### Mandatory Grounds for Refusal

Extradition shall not be granted under this Agreement in any of following circumstances:

1. The requested Party considers the offence for which the request for extradition is made by the requesting Party as a political offence. Reference to a political offence shall not include the following offences:

(a) the taking or attempted taking of the life or an attack on the person of a Head of State or Head of Government or a member of his or her family; or

(b) an offence in respect of which the Parties have the obligation to establish jurisdiction or extradite by reason of a multilateral international agreement to which they are both Parties, including, but not limited to, such agreements relating to genocide, terrorism or hostage-taking.

2. The requested Party has well-found reasons to suppose that the request for extradition made by the requesting Party aims to institute criminal proceedings against or execute punishment upon the person sought on account of race, religion, nationality or political opinion of that person, or that the position of the person sought in judicial proceedings will be prejudiced for any of the reasons mentioned above.

3. The offence for which the request for extradition is made is exclusively a military offence under the military law of the requesting Party which is not also an offence under ordinary criminal law.

4. The prosecution or the execution of punishment for the offence for which extradition has been sought has become barred by reason prescribed under the law of either Party including a law relating to lapse of time.

5. The requested Party has tried and convicted or acquitted the person sought in respect of the same offence, before the request for extradition is made.

6. If the judgment of the requesting Party has been rendered in absentia, the convicted person has not had sufficient notice of the trial or the opportunity to arrange for his or her defense and he or she has not had or will not have the opportunity to have the case retried in his or her presence.

## ARTICLE 4

### Discretionary Grounds for Refusal

Extradition may be refused under this Agreement in any of the following circumstances:

1. The requested Party in accordance with its law has jurisdiction over the offence for which the request for extradition is made. In this case, the competent authority of the requested Party shall institute proceeding against the person sought.

2. In exceptional cases, the requested Party, while also taking into account the seriousness of the offence and the interests of the requesting Party, deems that, because of the personal circumstances of the person sought, the extradition would be incompatible with humanitarian consideration.

3. The requested Party is in the process of the proceeding against the person sought in respect of the same offence.

4. If the person whose extradition is requested has been sentenced or would be liable to be tried or sentenced in the territory of the requesting Party by ad hoc court or tribunal.

5. If the person sought has been finally acquitted or convicted in a third State for the same offence for which extradition is requested and, if convicted, the sentence imposed has been fully enforced or is no longer enforceable.

## ARTICLE 5
### Extradition of Nationals

1. Each Party shall have the right to refuse extradition of its own nationals.

2. If extradition is not granted pursuant to paragraph 1 of this Article, the requested Party shall, at request of the requesting Party, submit the case to its competent authority for prosecution. For this purpose, the requesting Party shall submit documents and evidence relating to the case to the requested Party.

3. Notwithstanding paragraph 2 of this Article, the requested Party shall not be required to submit the case to its competent authority for prosecution if the requested Party has no jurisdiction over the offence.

4. Nationality shall be determined at the time of the commission of the offence for which extradition is requested.

## ARTICLE 6

## Channels of Communication

For the purpose of this Agreement, the Parties shall communicate through the diplomatic channels, unless otherwise provided for in this Agreement.

## ARTICLE 7

## Request for Extradition and Required Documents

1. A request for extradition shall be made in writing and shall be accompanied by the followings:

(a) documents, statements, or other types of information which describe the identity, including, if possible, a physical description, photograph, and/or fingerprints, the nationality and probable location of the person sought;

(b) a statement of the facts of the case, including the time and place of the commission of the offence, and the procedural history of the case;

(c) a statement of the laws describing the essential elements and the designation of the offence;

(d) a statement of the laws describing the punishment for the offence;

(e) a statement of the laws relating to the time limit on the prosecution or the execution of punishment of the offence; and

(f) the documents, statements or other types of information specified in paragraph 2 or 3 of this Article, as applicable.

2. When the request for extradition relates to a person sought for prosecution, it shall also be accompanied by:

(a) a copy of the warrant of arrest or detention issued by a judge or other competent judicial authority of the requesting Party;

(b) information establishing that the person sought is the person to whom the warrant of arrest or detention refers; and

(c) a statement of the acts or omissions alleged to constitute the offence and supporting evidence thereto such as would provide a reasonable ground to suspect that the person sought has committed the offence for which extradition is requested.

3. When the request for extradition relates to a person who has been found guilty, it shall also be accompanied by:

(a) a copy of the judgement rendered by a court of the requesting Party, setting out the conviction and the sentence imposed, the fact that the sentence is enforceable, and the extent to which the sentence remains to be served;

(b) a copy of the warrant of arrest, or a statement that the person is subject to detention on the basis of the judgement of conviction;

(c) information establishing that the person sought is the person found guilty;

(d) a statement of the acts or omissions constituting the offence for which the person was found guilty; and

(e) a statement as to the legal means available to the person to prepare his or her defense or to have the case retried in his or her presence, if the person has been convicted of an offence in his or her absence.

4. All the documents to be presented by the requesting Party pursuant to the provisions of this Agreement shall be officially signed or sealed and shall be accompanied by translation in the language of the requested Party or the English language.

**ARTICLE 8**

**Additional Information**

1. If the requested Party considers that the information furnished in support of a request for extradition is not sufficient in accordance with this Agreement to enable extradition to be granted, that Party may request that additional information be furnished within such time as it specifies. If the requesting Party fails to submit additional information within that period, it shall be considered as having renounced its request voluntarily. However, the requesting Party shall not be precluded from making a fresh request for the same purpose.

2. Where the person is released from custody in accordance with paragraph 1 of this Article, the requested Party shall notify the requesting Party as soon as practicable.

## ARTICLE 9

### Provisional Arrest

1. In case of urgency, one Party may request the other Party to take provisional arrest against the person sought. Such request may be submitted in writing through the diplomatic channels.

2. The request for provisional arrest shall be in writing and contain:

(a) a description of the person sought, including information about the nationality of that person;

(b) a statement of the location, if known, of the person sought;

(c) a brief statement of the facts of the case, including, if possible, the time and place of the commission of the offence;

(d) a description of the laws violated;

(e) a statement of the existence of a warrant of arrest or the judgement of conviction of the person sought; and

(f) a statement that a request for extradition for the person sought will follow.

3. The requesting Party shall be notified without delay of the result of its request.

4. Provisional arrest shall be terminated if, within a period of sixty days after the arrest of the person sought, the competent authority of the requested Party has not received the formal request for extradition and the supporting documents required by Article 7. The present paragraph does not preclude the possibility of the conditional release of the person prior to the expiration of the sixty days in the event that the requested Party

learns of any grounds for a mandatory or discretionary refusal or if the requesting Party revokes its request for extradition.

5. The fact that the person sought has been discharged from custody pursuant to paragraph 4 of this Article shall not prejudice the subsequent rearrest and extradition of that person if the extradition request and supporting documents are delivered at a later date.

**Article 10**

**Simplified Extradition**

When a person sought advises a court or other competent authorities of the requested Party that the person consents to an order for extradition being made, the requested Party may take all necessary measures to expedite the extradition to the extent permitted by its laws.

**ARTICLE 11**

**Decision on the Request**

1. The requested Party shall deal with the request for extradition pursuant to procedures provided by its own law, and shall promptly communicate its decision to the requesting Party.

2. Reasons shall be given for any complete or partial refusal of the request.

ARTICLE 12

Surrender of the Person Sought

1. If the extradition has been granted, the requested Party and the requesting Party shall decide through consultation on the implementation of the extradition. For this purpose, the requested Party shall inform the requesting Party of the length of the time for which the person sought was detained prior to the surrender.

2. The requesting Party shall be considered as renouncing request for extradition if it does not accept the person sought within fifteen days after the date on which the implementation of the extradition has been agreed, unless otherwise provided for in paragraph 3 of this Article. The requested Party shall set that person at liberty immediately and may refuse extradition for the same offence.

3. If one Party fails to surrender or accept the person sought within the agreed period for reasons beyond its control, the other Party shall be notified. The Parties shall decide through consultation on the implementation of the extradition again, and the provision of paragraph 2 of this Article shall apply.

**ARTICLE 13**

**Postponed or Temporary Surrender**

1. When the person sought is being proceeded against or is serving a sentence in the territory of the requested Party for an offence other than that for which extradition is requested, the requested Party may surrender the person sought or postpone surrender

until the conclusion of the proceedings or the service of the whole or any part of the sentence imposed. The requested Party shall inform the requesting Party of any postponement.

2. To the extent permitted by its law, where a person has been found extraditable, the requested Party may temporarily surrender the person sought for the purpose of prosecution to the requesting Party in accordance with conditions to be determined between the Parties. A person who is returned to the requested Party following a temporary surrender may be finally surrendered to the requesting Party to serve any sentence imposed, in accordance with the provisions of this Agreement.

## ARTICLE 14

### Request for Extradition Made by Several States

1. Where requests are received from two or more States, including the other Party, for the extradition of the same person either for the same offence or for different offences, the requested Party shall determine to which of those States the person is to be extradited and shall notify those States of its decision.

2. In determining to which State the person is to be extradited, the requested Party shall consider all relevant factors, including but not limited to:

(a) the nationality and the ordinary place of residence of the person sought;

(b) whether the requests were made pursuant to an agreement;

(c) the time and place of commission of each offence;

(d) the respective interests of the requesting States;

(e) the gravity of the offences;

(f) the nationality of the victim;

(g) the possibility of further extradition between the requesting States; and

(h) the respective dates of the requests.

## ARTICLE 15

### Rule for Specialty

1. A person extradited under this Agreement shall not be detained, tried, or punished in the requesting Party for any offence other than the offence for which extradition has been granted, unless the requested Party consents to the person's detention, trial, or punishment. For the consent referred to in this paragraph:

(a) the requested Party may require the submission of the documents stipulated in Article 7;

(b) statements made by the extradited person with respect to the offence, if any, shall be submitted to the requested Party; and

(c) the person extradited may be detained by the requesting Party for such a period of time as the requested Party may authorize, while the request for consents referred to in this Article is being processed.

2. A person extradited under this Agreement shall not be re-extradited by the requesting Party to a third State for an offence committed prior to the extradition of that person unless the requested Party consents.

3. A person extradited under this Agreement shall neither be detained, tried, or punished in the requesting Party for any offence other than the offence for which extradition has

been granted, nor be re-extradited to a third State, unless the extradited person:

(a) has voluntarily returned to the territory of the requesting Party after leaving it; or

(b) does not leave the territory of the requesting Party within thirty (30) days from the date on which that person is free to leave except under conditions beyond his or her control.

4. These stipulations shall not apply to offences committed after extradition.

## ARTICLE 16

### Handing over of Property

1. The requested Party shall, insofar as its law permits and at the request of the requesting Party, seize and upon the granting of the extradition hand over property:

(a) which may be required as evidence; or

(b) which has been acquired as a result of the offence.

2. The property mentioned in paragraph 1 of this Article shall be handed over even if extradition, having been granted, cannot be carried out due to the death, disappearance or escape of the person claimed.

3. When the said property is liable to seizure or confiscation in the territory of the requested Party, the requested Party may, in connection with pending criminal proceeding, temporarily retain it or hand it over on condition that it be returned.

4. Any right which the requested Party of any State or individual may have acquired in the said property shall be preserved. Where these rights exist, the property shall be returned without charge to the requested Party at its request, as soon as possible after the trial.

## ARTICLE 17

## Transit

1. To the extent permitted by its law, transportation of a person extradited from a third State to either Party through the territory of the other Party may be authorized upon a request in writing made through the diplomatic channel. The request shall contain a description of the person being transported, including his or her nationality, and a brief statement of the facts of the case. A person in transit may be held in custody during the period of transit.

2. Authorization for transit shall not be required when air transport is used and no landing is scheduled in the territory of the Party of transit. If an unscheduled landing occurs in the territory of that Party, it may require the other Party to furnish a request for transit as provided in paragraph 1 of this Article. The Party of transit shall detain the person to be transported until the transportation is continued provided that the request is received within ninety-six (96) hours of the unscheduled landing.

3. Authorization for transit shall include authorization for accompanying officials to obtain assistance from authorities in the Party of transit in maintaining custody.

## ARTICLE 18

### Notification of Result

The requesting Party shall notify in time the requested Party of the information relating to the prosecution against, the trial of and the execution of punishment upon the person sought or the re-extradition of that person to third State.

## ARTICLE 19

### Assistance and Expenses

1. The requested Party shall appear on behalf of the requesting Party and conduct and carry out any proceedings arising out of a request for extradition.

2. The requested Party shall meet the cost of any proceedings in its jurisdiction arising out of a request for extradition. The requested Party shall bear the costs incurred in its territory in connection with the arrest and detention of the person whose extradition is sought, or the seizure and surrender of property.

3. The requesting Party shall bear the costs incurred in conveying the person whose extradition is granted from the territory of the requested Party, including transit costs.

## ARTICLE 20

### Relationship with Multilateral Conventions

This Agreement shall not affect any rights enjoyed and any obligations assumed by the Parties under any multilateral Convention.

## ARTICLE 21

### Settlement of Disputes

Any dispute arising from the implementation or interpretation of this Agreement shall be settled by consultation or negotiation.

## ARTICLE 22

### Amendment

This Agreement may be amended upon request by either Party. Any amendment which has been agreed to by the Parties through diplomatic channel shall come into force on the date to be mutually agreed upon and shall form an integral part of this Agreement.

## ARTICLE 23

### Entry into Force and Termination of the Agreement

1. This Agreement shall enter into force thirty (30) days after the date on which the Parties have notified each other in writing that their respective requirements for the entry into force of this Agreement have been complied with.

2. This Agreement shall apply to requests made after its entry into force, even if the relevant offences occurred prior to the date on which it enters into force.

3. Either Party may terminate this Agreement by notice in writing through the diplomatic channel at any time. Termination shall take effect six (6) months after the date on which the notice is given.

IN WITNESS WHEREOF, the undersigned, being duly authorized by their respective Governments, have signed this Agreement.

DONE, in duplicate, at Phnom Penh on this 22... day of October, 2009 in Khmer, Korean, and English languages, all texts being equally authentic. In case of any divergence of interpretation of the Agreement, the English text shall prevail.

**For the Government of the Kingdom of Cambodia**



**For the Government of the Republic of Korea**

